# អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២២/១០/១៩៩៧ ស្តីពីការផ្ទេរឥណទាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦
- បានឃើញ អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែក ឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧
- បានឃើញ ប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយចរិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្ត បន្ទាប់មាន: លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃ ទី២៣ ខែមករា ឆ្នាំ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ និងលេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៥, លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១.** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌) ចំនួន ៦២២ លានរៀល (ប្រាំមួយរយម្ភៃពីរលានរៀល) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកជំពូក ៣១ របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧។

**មាត្រា២.** ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ដោះស្រាយគោលនយោបាយដល់ប្រជាពលរដ្ឋ ដែលតំរូវអោយរុះរើលំនៅដ្ឋានចាកចេញពីបុរីកីឡា។

**មាត្រា៣.** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។